ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការដាក់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១. នស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង មានការប្រែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក/ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ. បក. ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃថវិកាឧបសម្ព័ន្ធ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ. បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុងស្វយ័តរាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ. បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

www.pheakdeylaw.com

## សំរេច

**មាត្រា១:** ដាក់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានតួនាទី និង ភារកិច្ច ដូចមានចែងក្នុងជំពូកទី ១៩ មាត្រាទី ២១ នៃអនុក្រឹត្យ លេខ ០៤ អនក្រ. បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ជាអង្គភាពអនុវត្តន៍ថវិកាឧបសម្ព័ន្ធ ។

**មាត្រា២:** វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធផ្តល់សេវាបណ្តុះបណ្តាលរយៈពេលខ្លី រយៈពេលមធ្យមនូវជំនាញពាក់ព័ន្ធសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងថ្នាក់បរិញ្ញាប័ត្រ និង បរិញ្ញាប័ត្រជាន់ខ្ពស់ តាមរូបភាពបង់ថ្លៃ ។

**មាត្រា៣:** អង្គភាពនេះ ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យលេខ ៧០ អនក្រ. បក ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃថវិកាឧបសម្ព័ន្ធ ។

**មាត្រា៤:** វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និង ហិរញ្ញវត្ថុនៃរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៥:** វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំគំរោងចំណូល- ចំណាយថវិកាឧបសម្ព័ន្ធប្រចាំឆ្នាំ អោយបានត្រឹមត្រូវ និង ទាន់ពេលវេលា ដើម្បីបញ្ចូលក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។

**មាត្រា៦:** វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំនូវរបាយការណ៍ចំណូល- ចំណាយថវិកាឧបសម្ព័ន្ធប្រចាំត្រីមាសជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយបានទាន់ពេលវេលា និងនៅបំណាច់ឆ្នាំត្រូវបិទបញ្ជីបូកសរុបការទូទាត់ចំណូល- ចំណាយ ដើម្បីបញ្ចូលទៅក្នុងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗ ។

**មាត្រា៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- ឯកសារ - កាលប្បវត្តិ

បានយកសេចក្តីគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

www.pheakdeylaw.com